គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
Committee For Free And Fair Elections In Cambodia (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org
ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហេរញ្ញិក
និង នាយក **CCPCR**

កញ្ញា **ស៊ីវ ចាន់សែន**
**Mr. CHHIV You Meng**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **ស៊ីន សែត**
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ០១/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលជាសូចនាករច្បាស់លាស់ នៃការសង្កេតលើការអនុវត្ត កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៣ នៃរដ្ឋសភា

*ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៩*

ការអង្កេតរបស់គណៈកម្មាធិការខុមហ្វ្រែលរកឃើញថា រាជរដ្ឋាភិបាលក្នុងនីតិកាលទី៣ នៃរដ្ឋសភាបានសម្រេចការសន្យាដែលមានសូចនាករច្បាស់លាស់ [១] នៃកម្មវិធីនយោបាយបានចំនួនតែ **២៦%** (ចំនួន៥នៃសូចនាករច្បាស់លាស់១៩) ដែលសន្យារួមមាន**កំណើនសេដ្ឋកិច្ច ការតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការ ការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ការមិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករ និងការប្រកាន់ភ្ជាប់នូវគោលនយោបាយចិនតែមួយ** ។ ខណៈដែលការសន្យាដែលមានសូចនាករច្បាស់លាស់ ដែលរាជរដ្ឋាភិបាលមិនបានបំពេញមានរហូតដល់**៥៨%** (ចំនួន ១១ នៃសូចនាករច្បាស់លាស់) ដូចជា **ការបង្កើតគណៈកម្មាធិការជាតិសិទ្ធិមនុស្ស ការទទួលស្គាល់តួនាទីរបស់គណបក្សប្រឆាំង ការកសាងច្បាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយ និងច្បាប់ស្តីពីបាតុកម្ម**ដើម្បីឱ្យសភាអនុម័ត **ការធ្វើឱ្យតម្លៃប្រេងឥន្ធនៈប្រហាក់ប្រហែលនឹងប្រទេសជិតខាង**ជាដើម ។ ហើយ**១៦%** នៃសូចនាករច្បាស់លាស់ (ស្មើចំនួន ៣)គឺ រាជរដ្ឋាភិបាលបំពេញបានខ្លះតិចតួច ដែលការសន្យានេះគឺរួមមានកំណែទម្រង់ជាពិសេស**ច្បាប់ និងប្រព័ន្ធយុត្តិធម៌** ។

ការសន្យាមួយចំនួនដែលមិនទាន់សម្រេចបានក្នុងនីតិកាលទី៣រួមមានការបង្កើតគណៈកម្មាធិការជាតិសិទ្ធិមនុស្ស សេចក្តីព្រាងច្បាប់ស្តីពីបាតុកម្មនិងកូដកម្ម សេចក្តីព្រាងច្បាប់គ្រប់គ្រងកាស៊ីណូ មិនឃើញមានក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ នៃរដ្ឋសភានោះទេ ។

---

[១] មាន ៧៣ ចំនុចនៃកម្មវិធីនយោបាយ ប៉ុន្តែខុមហ្វ្រែលបានសង្កេតតែការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់ ។ ក្នុងន័យនេះ ខុមហ្វ្រែលបានកំណត់ការសន្យាដែលមានសូចនាករច្បាស់លាស់បានចំនួន ១៩ ។

ទោះបីយ៉ាងណា គណៈកម្មាធិការខុមហ្វ្រែល សូមវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលនីតិកាលទី៤ ដែលបានបង្កើតកម្មវិធីនយោបាយមាន ៤៨ចំនុច ។ ក្នុងនោះមានទុកចំនុចមួយចំនួននៃកម្មវិធីនយោបាយដែលមិនទាន់សម្រេចបានក្នុងនីតិកាលទី៣ ដូចជាការប្រយុទ្ធប្រឆាំងអំពើពុករលួយ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ជាដើម។ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ មានលក្ខណៈទូលំទូលាយ ប្រើពាក្យ" បន្ត ជំរុញ ពង្រឹង លើកស្ទួយ" ។ល។ និងភាគច្រើនមិនមានសូចនាករច្បាស់លាស់ច្រើនទេ បើធៀបកម្មវិធីនយោបាយអណត្តិទី៣ ដែលអាចធ្វើឱ្យមានការពិបាកក្នុងការវាយតម្លៃ និងតាមដានថា តើគណបក្សជាប់ឆ្នោត អ្នកតំណាងរាស្ត្រ និងរាជរដ្ឋាភិបាលបានបំពេញ ឬសម្រេចបានការសន្យារបស់ខ្លួនបានត្រឹមកម្រិតណា?

ដើម្បីពង្រឹងភាពជាម្ចាស់អំណាចរបស់អ្នកបោះឆ្នោត និងបំពេញបន្ថែមអោយច្បាស់លាស់ទៅលើកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ គណៈកម្មាធិការខុមហ្វ្រែលនឹងជំរុញអោយមានការចូលរួមពីម្ចាស់ឆ្នោតតាមសហគមន៍ និងមណ្ឌលក្នុងសិក្ខាសាលាទូទាំង ២៤ខេត្ត-រាជធានី ដើម្បីកំណត់សូចនាករច្បាស់លាស់សម្រាប់វិស័យអាទិភាពក្នុងខេត្ត។

*សម្រាប់ព័ត៌មានលំអិតស្តីពីលទ្ធផលនៃការអនុវត្តរបស់រាជរដ្ឋាភិបាលនីតិកាលទី៣ សូមមើលក្នុង:*

- "របាយការណ៍ឃ្លាំមើលការអនុវត្តកម្មវិធីនយោបាយដែលមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភា" ដែលបានភ្ជាប់មកជាមួយ ឬចូលក្នុងវេបសាយ: www.comfrel.org

*សម្រាប់ព័ត៌មានផ្សេងៗសូមទាក់ទង:*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៧